ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
លេខ ..........សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែ...... ឆ្នាំ ២០១៦

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា**

**កម្មវត្ថុ៖** ករណីសំណើសុំអនុញ្ញាតជាគោលការណ៍ផ្តល់ប្រាក់ឧបត្ថម្ភម៉ោងបន្ថែមចំនួន ៤២ ០០០៛០០ ក្នុងមួយម៉ោងជូនគ្រូឧទ្ទេសដែលបង្រៀនបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ និងគ្រូបង្រៀនកម្រិតមូលដ្ឋានតាមប្រព័ន្ធពន្លឿនឆ្ពោះទៅគ្រូបង្រៀនកម្រិតឧត្តមសិក្សា ។

**យោង៖** លិខិតលេខ ៣៨៦៧ អយក.ហវ ចុះថ្ងៃទី ២៦-០៧-២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមរដ្ឋមន្ត្រី**មេត្តាជ្រាបថា ដោយសារសកម្មភាពបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ និងគ្រូបង្រៀនកម្រិតមូលដ្ឋានតាមប្រព័ន្ធពន្លឿនឆ្ពោះទៅគ្រូបង្រៀនកម្រិតឧត្តមសិក្សា មានសារសំខាន់ក្នុងការគាំទ្រដល់វិធានការពង្រាយគ្រូចេញពីសាលាលើសគ្រូ និងដើម្បីលើកទឹកចិត្តគ្រូបង្រៀនតាមរយៈការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យនិងឯកភាពជាគោលការណ៍ដូចខាងក្រោម ៖

១- ឧបត្ថម្ភ ៣៥ ០០០៛០០ ក្នុងមួយម៉ោង ជូនគ្រូឧទ្ទេសដែលបង្រៀនបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ និងគ្រូបង្រៀនកម្រិតមូលដ្ឋានតាមប្រព័ន្ធពន្លឿនឆ្ពោះទៅគ្រូបង្រៀនកម្រិតឧត្តមសិក្សា ក្នុងឆ្នាំ ២០១៦ ។

២- សម្រាប់ឆ្នាំ២០១៧ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តតាមអត្រាដែលមានចែងក្នុងអនុក្រឹត្យកែសម្រួលអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៦ ស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែម សម្រាប់ការបង្រៀននៅគ្រឹះស្ថានសិក្សាសាធារណៈ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរតនាគារជាតិ
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798